California Department of HealthCareServices (DHCS)

P.O. Box 997413 MS 4721
Sacramento, CA 95899-7413
**(866) 866-0602** or (877) 735-2929 TTY/TTD
http://dhcs.ca.gov/privacyoffice



# ព័ត៌មានរបស់លោកអ្នក។ សិទ្ធិរបស់លោកអ្នក។ ការទទួលខុសត្រូវរបស់យើងខ្ញុំ។

ការជូនដំណឹងនេះពិពណ៌នាអំពីរបៀបប្រើប្រាស់ និង លាតត្រដាងព័ត៌មានសុខភាពរបស់លោកអ្នក និង របៀបដែលលោកអ្នកអាចទទួលបានព័ត៌មាននេះ។ **សូមពិនិត្យឡើងវិញដោយប្រុងប្រយ័ត្ន**

## សិទ្ធិរបស់លោកអ្នក

**នៅពេលនិយាយអំពីព័ត៌មានសុខភាពលោកអ្នក លោកអ្នក មានសិទ្ធិមួយចំនួន។** ផ្នែកនេះពន្យល់អំពីសិទ្ធិរបស់លោកអ្នក និងការទទួលខុសត្រូវមួយចំនួនរបស់យើងខ្ញុំ ដើម្បីជួយលោកអ្នក។

| | |
|---|---|
| **ទទួលសំណៅឯកសារស្តីអំពីសុខភាព និងការទាមទាររបស់លោកអ្នក** | • លោកអ្នកអាចសុំមើល ឬយកសំណៅឯកសារស្តីអំពីសុខភាព និងការទាមទាររបស់លោកអ្នក និងព័ត៌មានសុខភាពផ្សេងទៀតដែលយើងមាន ទាក់ទងនឹងលោកអ្នក។ សាកសួរយើងខ្ញុំពីរបៀបនៃការស្នើសុំ ។<br>• យើងខ្ញុំនឹងផ្តល់ជូនសំណៅឯកសារមួយច្បាប់ ឬ សេចក្តីសង្ខេបមួយច្បាប់នៃឯកសារស្តីអំពីសុខភាព និងការទាមទាររបស់លោកអ្នក ជាធម្មតាក្នុងរយៈពេល 30ថ្ងៃគិតចាប់ពីថ្ងៃស្នើសុំ។ យើងខ្ញុំអាចគិតកម្រៃសមរម្យ ផ្អែកលើការចំណាយ។ |
| **ស្នើសុំយើងខ្ញុំឲ្យកែតម្រូវឯកសារស្តីអំពីសុខភាព និងការទាមទារ** | • លោកអ្នកអាចស្នើសុំឲ្យយើងខ្ញុំកែតម្រូវឯកសារស្តីអំពីសុខភាព និងការទាមទាររបស់លោកអ្នកបាន ប្រសិនបើលោកអ្នកគិតថាឯកសារនេះមិនត្រឹមត្រូវ ឬមិនពេញលេញ។ សាកសួរយើងអំពីរបៀបនៃការស្នើសុំ។<br>• យើងខ្ញុំអាចនឹង "បដិសេធ" ចំពោះសំណើរបស់លោកអ្នក ប៉ុន្តែយើងខ្ញុំនឹងប្រាប់លោកអ្នកអំពីមូលហេតុជាលាយលក្ខណ៍អក្សរក្នុងរយៈពេល 60ថ្ងៃ។ |
| **ស្នើសុំទំនាក់ទំនងដោយសម្ងាត់** | • លោកអ្នកអាចស្នើសុំឲ្យយើងខ្ញុំទំនាក់ទំនងលោកអ្នកតាមវិធីជាក់លាក់មួយ ( ឧទាហរណ៍ ទូរស័ព្ទនៅផ្ទះ ឬការិយាល័យ ) ឬផ្ញើលិខិតទៅកាន់អាសយដ្ឋានផ្សេងទៀត។<br>• យើងខ្ញុំនឹងពិនិត្យរាល់សំណើសមស្របទាំងអស់ ហើយយើងខ្ញុំត្រូវតែឆ្លើយថា៖ "យល់ព្រម" ប្រសិនបើលោកអ្នកប្រាប់យើងខ្ញុំថា លោកអ្នកនឹងមានគ្រោះថ្នាក់ ប្រសិនបើយើងខ្ញុំមិនធ្វើតាមការស្នើសុំ។ |

*តនៅទំព័របន្ទាប់*

## សិទ្ធិរបស់លោកអ្នក *(បន្ត)*

| | |
|---|---|
| **ស្នើសុំឲ្យយើងខ្ញុំកម្រិតអ្វីដែលយើងខ្ញុំប្រើប្រាស់ ឬចែករំលែក** | • លោកអ្នកអាចស្នើឲ្យយើងខ្ញុំ**មិន**ប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពជាក់លាក់មួយចំនួនពាក់ព័ន្ធនឹងការព្យាបាល ឬការវះកាត់របស់យើងខ្ញុំ។<br>• យើងខ្ញុំមិនមានកាតព្វកិច្ចយល់ព្រមទៅនឹងសំណើរបស់លោកអ្នកទេ ហើយយើងខ្ញុំអាចនឹងឆ្លើយៈ "បដិសេធ" ប្រសិនបើសំណើនោះប៉ះពាល់ដល់ការថែទាំសុខភាពរបស់លោកអ្នក។ |
| **ទទួលបញ្ជីឈ្មោះអ្នកដែលយើងខ្ញុំបានចែករំលែកព័ត៌មានឲ្យ** | • លោកអ្នកអាចស្នើសុំបញ្ជី (គណនេយ្យ) នៃចំនួនដងដែលយើងខ្ញុំបានចែករំលែកព័ត៌មានសុខភាពរបស់លោកអ្នក ក្នុងរយៈពេល 6 ឆ្នាំមុនកាលបរិច្ឆេទដែលលោកអ្នកស្នើសុំ, អ្នកណាដែលយើងខ្ញុំបានចែករំលែកព័ត៌មាននោះ និងមូលហេតុ។<br>• យើងខ្ញុំនឹងបញ្ចូលរាល់ព័ត៌មានដែលបានបង្ហាញទាំងឡាយ លើកលែងតែព័ត៌មានទាក់ទងនឹងការព្យាបាល ការបង់ប្រាក់ និងតំហែទាំសុខភាព ព្រមទាំងព័ត៌មានដែលបានបង្ហាញផ្សេងទៀត (ដូចជាព័ត៌មានដែលលោកអ្នកបានស្នើឲ្យបើកចំហ)។ យើងខ្ញុំនឹងផ្តល់បញ្ជីគណនេយ្យមួយក្នុងមួយឆ្នាំដោយឥតគិតថ្លៃ ប៉ុន្តែយើងខ្ញុំនឹងគិតកម្រៃសេវាសមរម្យ ផ្អែកលើការចំណាយ ប្រសិនបើលោកអ្នកស្នើសុំបញ្ជីគណនេយ្យមួយផ្សេងទៀត ក្នុងរយៈពេល 12ខែ។ |
| **ទទួលសំណៅឯកសារមួយច្បាប់អំពីការជូនដំណឹងអំពីឯកជនភាពនេះ** | • លោកអ្នកអាចស្នើសុំឯកសារជូនដំណឹងនេះមួយច្បាប់ នៅពេលណាក៏បាន ទោះបីលោកអ្នកបានយល់ព្រមទទួលការជូនដំណឹងនេះតាមប្រព័ន្ធអេឡិចត្រូនិចក៏ដោយ។ យើងខ្ញុំនឹងផ្តល់ជូនលោកអ្នកនូវឯកសារនេះ មួយច្បាប់ភ្លាម។ |
| **ជ្រើសរើសអ្នកដែលធ្វើសកម្មភាពតំណាងឲ្យលោកអ្នក** | • ប្រសិនបើលោកអ្នកបានប្រគល់សិទ្ធិឲ្យអ្នកណាម្នាក់ជាតំណាងផ្នែកសុខភាព ឬ ប្រសិនបើអ្នកណាម្នាក់ជាអាណាព្យាបាលស្របច្បាប់របស់លោកអ្នក  បុគ្គលនោះអាចអនុវត្តសិទ្ធិរបស់លោកអ្នក និងជ្រើសរើសព័ត៌មានសុខភាពរបស់លោកអ្នកបាន។<br>• យើងខ្ញុំនឹងធ្វើឲ្យប្រាកដថាបុគ្គលនោះមានសិទ្ធិសម្រេចនេះ ហើយអាចធ្វើកិច្ចការតំណាងឲ្យលោកអ្នកមុននឹងយើងខ្ញុំចាត់វិធានការណាមួយ។ |
| **ប្តឹងទាមទារប្រសិនបើលោកអ្នកមានអារម្មណ៍ថា សិទ្ធិរបស់លោកអ្នកត្រូវបានបំពាន** | • លោកអ្នកអាចប្តឹងតវ៉ាបាន ប្រសិនបើលោកអ្នកមានអារម្មណ៍ថា យើងខ្ញុំបានរំលោភសិទ្ធិរបស់លោកអ្នក តាមរយៈទំនាក់ទំនងមកយើងខ្ញុំ ដោយប្រើប្រាស់ព័ត៌មាននៅលើទំព័រទី 1។<br>• លោកអ្នកអាចប្តឹងតវ៉ាជាមួយការិយាល័យសិទ្ធិស៊ីវិលនៃក្រសួងសុខាភិបាលនិងសេវាមនុស្សជាតិរបស់សហរដ្ឋអាមេរិក តាមរយៈផ្ញើលិខិតមួយច្បាប់ទៅកាន់អាសយដ្ឋាន 200 Independence Avenue, S.W., Washington, D.C. 20201, ទូរស័ព្ទទៅកាន់លេខ 1-877-696-6775 ឬចូលទៅកាន់គេហទំព័រ **www.hhs.gov/ocr/privacy/hipaa/complaints/** ។<br>• យើងខ្ញុំនឹងមិនសងសឹកប្រឆាំងនឹងលោកអ្នកចំពោះការប្តឹងតវ៉ានោះទេ។ |

## ជម្រើសនានារបស់លោកអ្នក

**សម្រាប់ព័ត៌មានជាក់លាក់អំពីសុខភាព លោកអ្នកអាចប្រាប់យើងខ្ញុំពីជម្រើសនានារបស់លោកអ្នក អំពីអ្វីដែលយើងចែករំលែក។** ប្រសិនបើលោកអ្នកមានចំណង់ចំណូលចិត្តច្បាស់លាស់មួយទាក់ទងនឹងរបៀបដែលយើងខ្ញុំចែករំលែកព័ត៌មានលោកអ្នក នៅក្នុងស្ថានភាពទាំងឡាយ ដែលរៀបរាប់ខាងក្រោម ចូរនិយាយមកកាន់យើងខ្ញុំ។ ប្រាប់យើងខ្ញុំនូវអ្វីដែលលោកអ្នកចង់ឲ្យយើងខ្ញុំធ្វើ ហើយយើងខ្ញុំនឹងអនុវត្តតាមការណែនាំរបស់លោកអ្នក។

| | |
|---|---|
| **នៅក្នុងករណីទាំងនេះ លោកអ្នកមានទាំងសិទ្ធិ មានទាំងជម្រើស ដើម្បីប្រាប់យើងខ្ញុំឲ្យ៖** | • ចែករំលែកព័ត៌មានជាមួយក្រុមគ្រួសារ មិត្តភ័ក្តជិតស្និទ្ធរបស់លោកអ្នក ឬអ្នកដទៃទៀតដែលពាក់ព័ន្ធនឹងការបង់ប្រាក់សម្រាប់ការថែទាំសុខភាពរបស់លោកអ្នក។<br>• ចែករំលែកព័ត៌មាននៅក្នុងស្ថានភាពជួយសង្គ្រោះគ្រោះមហន្តរាយ។<br>• ទំនាក់ទំនងលោកអ្នកដើម្បីខិតខំប្រឹងប្រែងរៃអង្គាសមូលនិធិ។<br>*ប្រសិនបើលោកអ្នកមិនអាចប្រាប់យើងខ្ញុំអំពីចំណង់ចំណូលចិត្តលោកអ្នក ឧទាហរណ៍ ប្រសិនបើលោកអ្នកសន្លប់មិនដឹងខ្លួន យើងខ្ញុំអាចដំណើរការទៅមុខ ហើយចែករំលែកព័ត៌មានលោកអ្នក ប្រសិនបើយើងខ្ញុំជឿជាក់ថាវាគឺដើម្បីផលប្រយោជន៍របស់លោកអ្នកដ៏ល្អបំផុត។ យើងខ្ញុំក៏អាចចែករំលែកព័ត៌មានលោកអ្នកបានដែរ នៅពេលចាំបាច់ដើម្បីបន្ធូរបន្ថយការគំរាមកំហែងធ្ងន់ធ្ងរ និងភ្លាមៗដល់សុខភាព និងសុវត្ថិភាព។* |
| **នៅក្នុងករណីទាំងនេះ យើងខ្ញុំមិនចែករំលែកព័ត៌មានលោកអ្នកទេ វៀរលែងតែលោកអ្នកផ្តល់ការអនុញ្ញាតឲ្យយើងខ្ញុំជាលាយលក្ខណ៍អក្សរ៖** | • គោលបំណងផ្សព្វផ្សាយទីផ្សារ<br>• ការលក់ព័ត៌មានលោកអ្នក |

## ការប្រើប្រាស់ និងការលាតត្រដាងព័ត៌មានយើងខ្ញុំ

**ជាធម្មតាតើយើងខ្ញុំប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាព ដោយវិធីណា?** ជាធម្មតាយើងខ្ញុំប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពលោកអ្នក តាមមធ្យោបាយដូចខាងក្រោម៖

| | | |
|---|---|---|
| **ជួយចាត់ចែងការព្យាបាលថែទាំសុខភាពដែលលោកអ្នកទទួល** | • យើងខ្ញុំអាចប្រើប្រាស់ព័ត៌មានសុខភាពលោកអ្នក និងចែករំលែកព័ត៌មាននេះជាមួយអ្នកជំនាញវិជ្ជាជីវៈដែលកំពុងព្យាបាលលោកអ្នក។ | *ឧទា. វេជ្ជបណ្ឌិតបញ្ជូនព័ត៌មានឲ្យយើងខ្ញុំអំពីផែនការធ្វើរោគវិនិច្ឆ័យនិងព្យាបាល ដើម្បីឲ្យយើងខ្ញុំអាចរៀបចំសេវាបន្ថែមបាន។* |
| **គ្រប់គ្រងអង្គភាពរបស់យើងខ្ញុំ** | • យើងខ្ញុំអាចប្រើប្រាស់ និងលាតត្រដាងព័ត៌មានរបស់លោកអ្នក ដើម្បីគ្រប់គ្រងអង្គភាពយើងខ្ញុំ ហើយទំនាក់ទំនងលោកអ្នកនៅពេលចាំបាច់។<br>• **យើងខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ព័ត៌មានហ្សេនេទិច ដើម្បីសម្រេចថាតើយើងខ្ញុំនឹងផ្តល់ជូនលោកអ្នកនូវធានារ៉ាប់រង និងតម្លៃនៃធានារ៉ាប់រងនោះទេ។** នេះមិនអនុវត្តចំពោះផែនការថែទាំសុខភាពរយៈពេលវែងនោះទេ។ | *ឧទា. យើងខ្ញុំប្រើប្រាស់ព័ត៌មានសុខភាពលោកអ្នក ដើម្បីបង្កើតសេវាឲ្យកាន់តែល្អប្រសើរសម្រាប់លោកអ្នក។* |
| **ទូទាត់ឲ្យថ្លៃសេវាសុខភាពលោកអ្នក** | • យើងខ្ញុំអាចប្រើប្រាស់ និងលាតត្រដាងព័ត៌មានសុខភាពលោកអ្នក នៅពេលយើងខ្ញុំទូទាត់សេវាសុខភាពរបស់លោកអ្នក។ | *ឧទា. យើងខ្ញុំចែករំលែកព័ត៌មានអំពីលោកអ្នកជាមួយគម្រោងថែទាំសុខភាពធ្មេញរបស់លោកអ្នក ដើម្បីសម្របសម្រួលដល់ការទូទាត់ឲ្យថ្លៃសេវាព្យាបាលធ្មេញរបស់លោកអ្នក។* |
| **គ្រប់គ្រងដំណើរការគម្រោងរបស់លោកអ្នក** | • យើងខ្ញុំអាចលាតត្រដាងព័ត៌មានសុខភាពរបស់លោកអ្នកដល់អ្នកឧបត្ថម្ភគម្រោងសុខភាពរបស់លោកអ្នក ដើម្បីគ្រប់គ្រងដំណើរការគម្រោង។ | *ឧទា. ក្រុមហ៊ុនលោកអ្នកចុះកិច្ចសន្យាជាមួយយើងខ្ញុំ ដើម្បីផ្តល់គម្រោងសុខភាព ហើយយើងខ្ញុំផ្តល់ស្ថិតិជាក់លាក់មួយចំនួនដល់ក្រុមហ៊ុនរបស់លោកអ្នក ដើម្បីពន្យល់អំពីការគិតប្រាក់បុព្វលាភធានារ៉ាប់រង។* |

*តនៅទំព័របន្ទាប់*

**តើយើងខ្ញុំអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានសុខភាពរបស់លោកអ្នកដូចម្ដេចទៀត?** យើងខ្ញុំត្រូវបានអនុញ្ញាត ឬតម្រូវឲ្យចែករំលែកព័ត៌មានរបស់លោកអ្នកតាមមធ្យោបាយផ្សេងៗ ជាធម្មតាតាមមធ្យោបាយទាំងឡាយ ដែលជាវិភាគទានដល់ផលប្រយោជន៍សាធារណៈ ដូចជា ការស្រាវជ្រាវ និងសុខភាពសាធារណៈ។ យើងខ្ញុំត្រូវតែបំពេញតាមលក្ខខណ្ឌជាច្រើននៅក្នុងច្បាប់ មុនពេលយើងខ្ញុំអាចចែករំលែកព័ត៌មានសម្រាប់គោលបំណងទាំងនេះបាន។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖ www.hhs.gov/ocr/privacy/hipaa/understanding/consumers/index.html.

| | |
|---|---|
| **ជួយដល់បញ្ហាសុវត្ថិភាព និងសុខភាពសាធារណៈ** | • យើងខ្ញុំអាចចែករំលែកព័ត៌មានសុខភាពអំពីលោកអ្នកសម្រាប់ស្ថានភាពជាក់លាក់មួយចំនួនដូចជា៖<br>  • បង្ការជំងឺ<br>  • ជួយដល់ការប្រមូលផលិតផលមកវិញ<br>  • រាយការណ៍ប្រតិកម្មអវិជ្ជមានចំពោះការប្រើប្រាស់ឱសថ<br>  • រាយការណ៍ការសង្ស័យអំពីការរំលោភបំពាន ការធ្វេសប្រហែស ឬអំពើហិង្សាក្នុងគ្រួសារ<br>  • បង្ការ ឬបន្ថយការគំរាមកំហែងធ្ងន់ធ្ងរដល់សុខភាព ឬសុវត្ថិភាពរបស់អ្នកណាម្នាក់ |
| **ធ្វើសិក្សាស្រាវជ្រាវ** | • យើងខ្ញុំអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់លោកអ្នកសម្រាប់ការស្រាវជ្រាវសុខភាព។ |
| **គោរពតាមច្បាប់** | • យើងខ្ញុំនឹងចែករំលែកព័ត៌មានអំពីលោកអ្នក ប្រសិនបើរដ្ឋ ឬច្បាប់សហព័ន្ធតម្រូវឲ្យ រួមទាំងក្រសួងសុខាភិបាល និងសេវាមនុស្សជាតិ ប្រសិនបើគេត្រូវការ។ |
| **ឆ្លើយតបទៅនឹងសំណើសុំបរិច្ចាគកោសិកា និងសរីរាង្គ និងធ្វើការជាមួយអ្នកត្រួតពិនិត្យវេជ្ជសាស្ត្រ ឬអ្នកគ្រប់គ្រងបុណ្យសព។** | • យើងខ្ញុំអាចចែករំលែកព័ត៌មានសុខភាពអំពីលោកអ្នកជាមួយអង្គភាពទិញសរីរាង្គ។<br>• យើងខ្ញុំអាចចែករំលែកព័ត៌មានសុខភាពជាមួយ អ្នកធ្វើកោសលវិច័យសព អ្នកត្រួតពិនិត្យវេជ្ជសាស្ត្រ ឬអ្នកគ្រប់គ្រងបុណ្យសព នៅពេលបុគ្គលណាម្នាក់ស្លាប់។ |
| **ដោះស្រាយសំណងកម្មករ ការអនុវត្តច្បាប់ សំណើផ្សេងៗទៀតរបស់រដ្ឋាភិបាល** | • យើងខ្ញុំអាចប្រើប្រាស់ ឬចែករំលែកព័ត៌មានអំពីលោកអ្នក៖<br>  • សម្រាប់ការទាមទារសំណងកម្មករ។<br>  • សម្រាប់គោលបំណងនៃការអនុវត្តច្បាប់ ឬជាមួយមន្ត្រីអនុវត្តន៍ច្បាប់<br>  • ទីភ្នាក់ងារទទួលបន្ទុកសុខាភិបាលសម្រាប់ សកម្មភាពនានាដែលច្បាប់បានអនុញ្ញាត<br>  • សម្រាប់មុខនាទីពិសេសរបស់រដ្ឋាភិបាល ដូចជា យោធា សន្តិសុខជាតិ និងសេវាការពារប្រធានាធិបតី |
| **ឆ្លើយតបទៅនឹងបណ្ដឹង និងចំណាត់ការតាមផ្លូវច្បាប់** | • យើងខ្ញុំអាចចែករំលែកព័ត៌មានសុខភាពអំពីលោកអ្នក ជាការឆ្លើយតបទៅនឹងតុលាការ ឬបទបញ្ជារដ្ឋបាល ឬឆ្លើយតបទៅនឹងដីកាកោះ។ |
| **ការផ្សព្វផ្សាយ ការចុះឈ្មោះ កិច្ចសម្របសម្រួលការថែទាំ និងការគ្រប់គ្រងករណី** | • យើងខ្ញុំអាចចែករំលែកព័ត៌មានរបស់លោកអ្នកជាមួយកម្មវិធីអត្ថប្រយោជន៍ដទៃៗទៀតរបស់រដ្ឋាភិបាល ដូចជា Covered California ដើម្បីហេតុផលនៃការផ្សព្វផ្សាយ ការចុះឈ្មោះ កិច្ចសម្របសម្រួលការថែទាំ និងការគ្រប់គ្រងករណី។ |
| **ការតវ៉ាចំណោះការសម្រេចរបស់ DHCS** | • យើងខ្ញុំអាចចែករំលែកព័ត៌មានរបស់លោកអ្នក ប្រសិនបើលោកអ្នក ឬអ្នកផ្ដល់សេវារបស់លោកអ្នកតវ៉ាចំពោះសេចក្ដីសម្រេច DHCS អំពីការថែទាំសុខភាពអ្នកលោក។ |
| **ដាក់ពាក្យស្នើសុំ Medi-Cal ទាំងស្រុង** | • ប្រសិនបើលោកអ្នកដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ Medi-Cal ទាំងស្រុង យើងខ្ញុំត្រូវតែពិនិត្យឋានភាពអន្តោប្រវេសន៍លោកអ្នកជាមួយនឹងស្ថាប័នសេវាកម្មអន្តោប្រវេសន៍ និងសញ្ជាតិសហរដ្ឋអាមេរិក (USCIS)។ |
| **ចូលរួមគម្រោងថែទាំសុខភាពដែលមានការគ្រប់គ្រង** | • ប្រសិនបើលោកអ្នកនឹងចូលរួមគម្រោងថែទាំសុខភាពដែលមានការគ្រប់គ្រងមួយ យើងខ្ញុំអាចចែករំលែកព័ត៌មានរបស់លោកអ្នកជាមួយគម្រោងនោះ សម្រាប់ហេតុផលកិច្ចសម្របសម្រួលការថែទាំសុខភាព និងដើម្បីធ្វើឲ្យប្រាកដថា លោកអ្នកអាចទទួលសេវានោះបានទាន់ពេលវេលា។ |

*តនៅទំព័របន្ទាប់*

| | |
|---|---|
| **គ្រប់គ្រងដំណើរការកម្មវិធីនានារបស់យើងខ្ញុំ** | • យើងខ្ញុំអាចចែករំលែកព័ត៌មានរបស់លោកអ្នកជាមួយអ្នកម៉ៅការ និងភ្នាក់ងាររបស់យើងខ្ញុំ ដែលពួក គាត់ជាអ្នកជួយគ្រប់គ្រងដំណើរការកម្មវិធីនានារបស់យើងខ្ញុំ។ |
| **គោរពតាមច្បាប់ពិសេសៗ** | • មានច្បាប់ពិសេសៗដែលការពារប្រភេទមួយចំនួននៃព័ត៌មានសុខភាព ដូចជា សេវាសុខភាពផ្លូវចិត្ត ការព្យាបាលដំណើរខុសប្រក្រតីពីការប្រើប្រាស់សារធាតុ ការធ្វើតេស្តហ៊ីវ/អេដស៍ និងការព្យាបាល។ យើងខ្ញុំនឹងគោរពតាមច្បាប់ទាំងនេះ នៅពេលដែល មានដាក់កំហិតតឹងតែងជាងការជូនដំណឹងនេះ។ |

យើងខ្ញុំនឹងមិនលក់ដូរព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកទេ។

## ការទទួលខុលត្រូវរបស់យើងខ្ញុំ

- ច្បាប់តម្រូវឲ្យយើងខ្ញុំរក្សាឯកជនភាព និងសន្តិសុខនៃព័ត៌មានសុខភាពដែលត្រូវបានការពាររបស់លោកអ្នក។
- យើងខ្ញុំនឹងជូនដំណឹងឲ្យលោកអ្នកបានដឹងភ្លាមៗ ប្រសិនបើមានការរំលោភបំពានណាមួយកើតឡើងដែលអាចប៉ះពាល់ដល់ឯកជនភាព ឬសន្តិសុខព័ត៌មានរបស់លោកអ្នក។
- យើងខ្ញុំត្រូវតែអនុវត្តភារកិច្ចទាំងឡាយ និងការអនុវត្តន៍ឯកជនភាព ដែលមានរៀបរាប់នៅក្នុងការជូនដំណឹងនេះ និងផ្តល់ជូនលោកអ្នកនូវឯកសារនេះមួយច្បាប់។
- យើងខ្ញុំនឹងមិនប្រើប្រាស់ ឬចែករំលែកព័ត៌មានរបស់លោកអ្នកក្រៅពីអ្វីដែលបានរៀបរាប់នៅទីនេះទេ វៀរលែងតែលោកអ្នកប្រាប់យើងខ្ញុំជាលាយលក្ខណ៍អក្សរថា យើងខ្ញុំអាចធ្វើទៅបាន។ ប្រសិនបើលោកអ្នកប្រាប់យើងខ្ញុំថា យើងខ្ញុំអាចធ្វើទៅបាន លោកអ្នកអាចផ្លាស់ប្តូរគំនិតរបស់ខ្លួននៅពេលណាក៏បាន។ សូមឲ្យយើងខ្ញុំដឹងជាលាយលក្ខណ៍អក្សរ ប្រសិនបើលោកអ្នកផ្លាស់ប្តូរគំនិតរបស់លោកអ្នក។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖
www.hhs.gov/ocr/privacy/hipaa/understanding/consumers/noticepp.html.

### ការផ្លាស់ប្តូរលក្ខខណ្ឌនៃការជូនដំណឹងនេះ

យើងខ្ញុំអាចផ្លាស់ប្តូរលក្ខខណ្ឌនៃការជូនដំណឹងនេះ  ហើយការផ្លាស់ប្តូរនេះនឹងអនុវត្តលើរាល់ព័ត៌មានទាំងឡាយដែលយើងខ្ញុំមានអំពីលោកអ្នក។ ការជូនដំណឹងថ្មីនឹងផ្តល់ជូនបានតាមការស្នើសុំ នៅលើគេហទំព័ររបស់យើងខ្ញុំ ហើយយើងខ្ញុំនឹងផ្ញើមួយច្បាប់ជូនលោកអ្នក។

កាលបរិច្ឆេទអនុវត្ត: ថ្ងៃទី23 ខែកញ្ញា ឆ្នាំ2013

### ការជូនដំណឹងអំពីការរក្សាភាពសម្ងាត់នេះអនុវត្តចំពោះ អង្គភាពទាំងឡាយដូចខាងក្រោម៖

- ការជូនដំណឹងនេះអនុវត្តចំពោះកម្មវិធី DHCS ទាំងអស់ រួមទាំង Medi-Cal ផងដែរ។ សម្រាប់បញ្ជីទាំងស្រុងនៃកម្មវិធីទាំងឡាយដែលបច្ចុប្បន្នគ្រប់គ្រងដោយ DHCS សូមអញ្ជើញចូលទៅកាន់គេហទំព័រ របស់យើងខ្ញុំ www.dhcs.ca.gov/services។

### សម្រាប់ព័ត៌មានបន្ថែម

សូមអញ្ជើញទំនាក់ទំនងយើងខ្ញុំដើម្បីស្នើសុំការជូនដំណឹងនេះមួយច្បាប់ជាភាសាមួយផ្សេងទៀត ឬដើម្បីទទួលឯកសារនេះមួយច្បាប់ជាទម្រង់ផ្សេងទៀត ដូចជា អត្ថបទបោះពុម្ពធំៗ ឬអត្ថបទជាអក្សរផុស (Braille)។

DHCS មិនមានឯកសារសុខភាពរបស់លោកអ្នកទាំងស្រុងទេ។ ប្រសិនបើលោកអ្នកចង់មើល ហើយចង់បានមួយច្បាប់ ឬចង់ផ្លាស់ប្តូរឯកសារសុខភាពរបស់លោកអ្នក សូមអញ្ជើញទំនាក់ទំនងវេជ្ជបណ្ឌិត ទន្តពេទ្យរបស់លោកអ្នក ឬគម្រោងសុខភាពជាមុនសិន។

**មន្ត្រីផ្នែកឯកជនភាពរបស់ DHCS**
P.O. Box 997413 MS 4721
Sacramento, CA 95899-7413

ទូរស័ព្ទ: **(866) 866-0602** ជម្រើស 1 ឬ (877) 735-2929 TTY/TTD
ទូរសារ: (916) 327-4556
អ៊ីម៉ែល: privacyofficer@dhcs.ca.gov